# ការអំពាវនាវរបស់លោក សម រង្ស៊ី ?

លោក សម រង្ស៊ី អំពាវនាវ ចំពោះកងទ័ព អោយងើបប្រឆាំងនឹង ហ៊ុន សែន ដោយសន្យាថា នឹងមានថវិកា សំរាប់ប្រដុងប្រជា នៃការប៉ះបោរនោះ។ លក្ខណៈ នៃការអំពាវនាវនេះ វាមាន តក្កសាស្ត្រ នៃសង្គ្រាម ព្រោះវាជាការងើបប្រឆាំងដោយប្រដាប់អាវុធ បើសិន ហ៊ុន សែន ប្រើកងទ័ព ដែលស្ម័គ្រគ្មានលក្ខខណ្ឌនឹងគាត់ មកបង្រ្កាប។ សួរថា តើកងទ័ព ដែលស្ម័គ្រនឹង សម រង្ស៊ី ឬ ប្រជាជនប្រឆាំងនឹង ហ៊ុន សែន មានកាំភ្លើង និង គ្រាប់គ្រប់គ្រាន់ដើម្បីតស៊ូបានដែរឬទេ ? តើ សម រង្ស៊ី យល់ដឹងថា នៅស្រុកខ្មែរ វាគ្មានកងទ័ពជាតិនោះឡើយ ព្រោះស្រុកខ្មែរជាប្រទេសមួយគ្មានរដ្ឋ, ព្រោះ រដ្ឋ និង គ្រប់ស្ថាប័នរដ្ឋ វាជាបក្សប្រជាជន។ មួយវិញទៀត វាមានកងទ័ពយួន លាក់ខ្លួននៅក្នុងកងទ័ពបក្ស ឬ ចេញមុខនៅលើទឹកដីខ្មែរ តើ សម រង្ស៊ី ស្គាល់ប្រតិកម្មកងទ័ពនេះដែរឬទេ នៅចំពោះមុខព្រឹត្តិការណ៍ ដែលគាត់ប្រកាសថា គាត់នឹងធ្វើឱ្យកើតមាន ដើម្បីឱ្យ ហ៊ុន សែន ដើរតាមគាត់ ? ការលើកយកឈ្មោះ ជា ស៊ីម, ស ខេង មកធ្វើជា បំណើកនៃនយោបាយ និង គម្នាស់នៃយុទ្ធសាស្ត្រ តើវាអាចចាត់ទុក សម រង្ស៊ី ជាអ្នកប្រជាធិតេយ្យនិយមបានដែរឬទេ ? តែយើង ក៏មិនយល់ឃើញស្រាល លើគោលបំណងប្រកាន់មាំរបស់ សម រង្ស៊ី នោះដែរ។ ក៏ប៉ុន្តែ កត្តាចម នៅក្នុងនាដកថា (scénario) នេះ គឺប្រជាពលរដ្ឋខ្មែរ, តើគាត់បានត្រៀមខ្លួនរួចរាល់ហើយឬនៅ ក្នុងសមរភូមិយោធា ?